


# CSAJ Essay Contest 2014

*Cambodian Students Association in Japan (CSAJ) would like to announce its annual essay contest for the year 2014. The CSAJ Essay Contest aims to engage Cambodian youth in issues of social and personal development and to allow them to express their concerns and solutions publicly.*

## We would like to hear your views on ONE of the following five topics:

1. Traffic accident is one of the most serious problems occurred in Cambodia. It kills thousands of people every year. Drunk driving is considered as the main cause of traffic accidents in Cambodia. What should be done to reduce drunk-driving behavior in Cambodia?
2. Explain the advantages and disadvantages of Cambodia joining ASEAN Community 2015. Do you think it is the right time for us to attend that?
3. As a youth, do you think it is important to observe government policies? Justify your standpoint.
4. Some people argue that, as a developing country, poor implementation of copyright law allows our people to gain access to expensive and useful contents (music, movies, PC software…etc.) at a lower price. However, some argue that poor protection of copyrights could discourage innovation and defame our nation's images. Do you think to what extent Cambodia should strengthen its copyrights law enforcement? Why?
5. The former US President John F. Kennedy once said, "Ask not what your country can do for you, but what you can do for your country". What is your perspective towards this view?

## Awards

- 1st Prize: 200USD, gold medal + certificate
- 2nd Prize:150USD, silver medal + certificate
- 3rd Prize:100USD, bronze medal + certificate
- 7 finalists: 50USD each + certificate.

## Eligibility

1. Be Cambodian and is residing in Cambodia;
2. Not older than 23 years of age as of August 30th 2014;
3. Not the winner in CSAJ's previous contests.

## Requirements: Essay must

- Be written in either Khmer (1500-3000 words) or English (800-1600 words); annotations is not counted
- Be type-written, double-spaced (A4 size paper)
- Be the original work of the contestant, no plagiarism. Use of other people's work must be properly cited, or it will result in disqualification from this contest
- Include full name, affiliation, email address, and phone number of the contestant.

## How to submit your essay

Please submit your essay in MS Word or PDF format via email to: essay14@csaj-khmer.org by **July 25th 2014, no later 24:00pm** (time in Cambodia). Please write 'CASJ Essay Contest 2014' in the subject of your email.

## Schedule

- July 25th, 2014 : Submission deadline
- August 14th, 2014 : Announcement of 10 finalists
- August 30th, 2014 : Final presentation and selection of 3 winners to be held in Phnom Penh.

Note: Announcement of the 10 finalists will be posted on http://essaycontest.csaj-khmer.org. The finalists will also be contacted by email or phone for final presentation.

## Selection Process

CSAJ Essay Contest 2014 Commission will select the top ten essays for the final round based on the essay's content, style, clarity and how well you support your arguments. Final jury will select three winning essays on August 30th, 2014 to be held in Phnom Penh, Cambodia.

For more information, please visit our website: http://essaycontest.csaj-khmer.org or contact us via email: essay14@csaj-khmer.org or call us: (+81)-80-4816-8986 (Japan).

*Copyright @ 2014 by Cambodian Students Association in Japan*




# ការប្រកួតសរសេរអត្ថបទតែងសេចក្តីប្រចាំឆ្នាំ២០១៤

*សមាគមនិស្សិតខ្មែរនៅប្រទេសជប៉ុន(CSAJ)សូមជូនដំណឹងដល់សាធារណជនអំពីការប្រកួតតែងអត្ថបទប្រចាំឆ្នាំ២០១៤។ ការប្រកួតនេះធ្វើឡើងជារៀងរាល់ឆ្នាំ ក្នុងគោលបំណងជួយឲ្យយុវជនកម្ពុជាអាចចូលរួមចំណែកក្នុងការអភិវឌ្ឍខ្លួនឯង និងសង្គម ព្រមទាំងអាចបញ្ចេញមតិ និងដំណោះស្រាយជាសាធារណៈនូវបញ្ហាសង្គមនានា។*

## បេក្ខជន ឬបេក្ខនារីអាចជ្រើសរើសប្រធានបទមួយក្នុងចំណោមប្រធានបទទាំងប្រាំខាងក្រោម៖

1. គ្រោះថ្នាក់ចរាចរណ៍គឺជាបញ្ហាចម្បងមួយក្នុងចំណោមបញ្ហានានាដែលកំពុងកើតមានក្នុងប្រទេសកម្ពុជា និងសំលាប់ជីវិតមនុស្សរាប់ពាន់នាក់ជារៀងរាល់ឆ្នាំ។ ការបើកបរក្នុងពេលស្រវឹងត្រូវបានគេឃើញថាជាមូលហេតុសំខាន់នៃគ្រោះថ្នាក់ចរាចរណ៍។ តើអ្នកគិតថាអ្វីខ្លះអាចជាដំណោះស្រាយលើបញ្ហាបើកបរក្នុងពេលស្រវឹងនេះបាន?
2. ចូរពន្យល់អំពីគុណសម្បត្តិ និងគុណវិបត្តិ ប្រសិនបើប្រទេសកម្ពុជាចូលខ្លួនក្នុងសហគមន៍អាស៊ាន(ASEAN Community) ឆ្នាំ២០១៥។ តើអ្នកគិតថាវាជាពេលវេលាសមស្របសម្រាប់កម្ពុជាដែរ ឬទេ?
3. ក្នុងនាមជាយុវជន តើអ្នកគិតថា វាជាការចាំបាច់ ឬទេក្នុងការសង្កេត និងតាមដានគោលនយោបាយរបស់រដ្ឋាភិបាល? ចូរផ្តល់អំណះអំណាងគាំទ្រមតិរបស់អ្នក។
4. មតិខ្លះលើកឡើងថា សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ភាពធូររលុងនៃច្បាប់កម្មសិទ្ធិបញ្ញា ផ្តល់ឱកាសឲ្យប្រជាជន អាចទទួលបានផលិតផលមានប្រយោជន៍ដូចជា ថាសចាក់ចម្រៀង រឿងកុន កម្មវិធីកុំព្យូទ័រជាដើម ក្នុងតម្លៃថោក។ ប៉ុន្តែ មតិខ្លះបែរជាគិតថាការមិនអនុវត្តតឹងរឹងនូវច្បាប់កម្មសិទ្ធិ បញ្ញាអាចជាមូលហេតុធ្វើឲ្យអ្នកផលិតមិនចង់ផលិតគ្មានភាពច្នៃប្រឌិតថ្មី និងអាចប៉ះពាល់ដល់កិត្តិយស ប្រទេសជាតិ។ តើអ្នកគិតថា ប្រទេសកម្ពុជាគួរពង្រឹងការ អនុវត្តច្បាប់កម្មសិទ្ធិបញ្ញាក្នុងកម្រិតណា? ហេតុអ្វី?
5. អតីតប្រធានាធិបតីអាមេរិក John F. Kennedy បាននិយាយថា "កុំសួរថាតើប្រទេសអ្នកអាចធ្វើអ្វីបានសម្រាប់អ្នក ប៉ុន្តែត្រូវសួរតើអ្នកអាចធ្វើអ្វីខ្លះសម្រាប់ប្រទេសអ្នក។" តើអ្នកគិតដូចម្តេចចំពោះការលើកឡើងបែបនេះ?

## រង្វាន់

- ជ័យលាភីលេខ១៖ ទឹកប្រាក់ 200USD មេដាយមាស និងលិខិតសរសើរ
- ជ័យលាភីលេខ២៖ ទឹកប្រាក់ 150USD មេដាយប្រាក់ និងលិខិតសរសើរ
- ជ័យលាភីលេខ៣៖ ទឹកប្រាក់ 100USD មេដាយសំរិទ្ធ និងលិខិតសរសើរ
- អ្នកសរសេរបានល្អបន្ទាប់៧រូប៖ ទឹកប្រាក់ 50USD និងលិខិតសរសើរ

## លក្ខខណ្ឌនៃការចូលរួម

1. មានសញ្ជាតិកម្ពុជា និងកំពុងស្នាក់នៅកម្ពុជា
2. មានអាយុមិនលើសពី២៣ឆ្នាំ គិតត្រឹមថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៤
3. មិនធ្លាប់ជាជ័យលាភីនៃការប្រកួតឆ្នាំមុនៗរបស់ CSAJ

## លក្ខខណ្ឌនៃការសរសេរអត្ថបទតែងសេចក្តី

- អត្ថបទជាភាសាខ្មែរ (១៥០០ ទៅ ៣០០០ពាក្យ) ឬជាភាសាអង់គ្លេស (៨០០ ទៅ១៦០០ពាក្យ)
- សរសេរដោយកុំព្យូទ័រ ដោយសរសេរមួយជួររំលងមួយជួរ (double-spaced) (ក្រដាសA4)
- ជាអត្ថបទផ្ទាល់ខ្លួនគ្មានការចម្លងស្នាដៃអ្នកដទៃ។ ប្រសិនបើដកស្រង់ផ្នែកណាមួយពីស្នាដៃអ្នកដទៃត្រូវមានដាក់ឯកសារយោងឲ្យបានត្រឹមត្រូវ បើពុំនោះទេអត្ថបទនោះអាចនឹងត្រូវដកចេញពីការប្រកួតនេះ
- អត្ថបទត្រូវភ្ជាប់ជាមួយនូវឈ្មោះ ទីកន្លែងសិក្សាឬធ្វើការ អ៊ីមែល និងលេខទូរស័ព្ទទំនាក់ទំនង របស់បេក្ខជន ឬបេក្ខនារី

## របៀបផ្ញើអត្ថបទមកចូលរួមប្រកួត

សូមផ្ញើអត្ថបទតែងសេចក្តីរបស់អ្នកជា MS Word ឬ PDF format មកកាន់អ៊ីមែល៖ essay14@csaj-khmer.org ឲ្យបានមុន**ម៉ោង២៤:០០ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤**។ នៅពេលផ្ញើសូមសរសេរ "CSAJ Essay Contest 2014" នៅត្រង់ Subject នៃអ៊ីមែលរបស់អ្នក។

## កាលវិភាគ

- ២៥ កក្កដា ២០១៤៖ ផុតកំណត់នៃការផ្ញើអត្ថបទ
- ១៤ សីហា ២០១៤៖ ប្រកាសលទ្ធផលអ្នកជាប់វគ្គជំរុះដំបូងចំនួន១០រូប
- ៣០ សីហា ២០១៤៖ ការធ្វើបទបង្ហាញដោយអ្នកជាប់ទាំង១០រូប និងប្រកាសលទ្ធផលជ័យលាភី៣រូប ព្រមទាំងពិធីចែករង្វាន់នៅទីក្រុងភ្នំពេញ

សំគាល់៖ លទ្ធផលនៃវគ្គជំរុះដំបូងចំនួន១០រូបនឹងត្រូវប្រកាសនៅលើគេហទំព័រ http://essaycontest.csaj-khmer.org ហើយបេក្ខជន-បេក្ខនារីដែលជាប់នោះនឹងត្រូវបានទាក់ទងតាមរយៈទូរស័ព្ទ ឬអ៊ីមែលដើម្បីមកធ្វើបទបង្ហាញនៅវគ្គចុងក្រោយ។

## ដំណាក់កាលនៃការជ្រើសរើស

អត្ថបទល្អជាងគេចំនួន១០នឹងត្រូវបានជ្រើសរើសដោយផ្អែកលើខ្លឹមសារ រចនាបថ ភាពច្បាស់លាស់នៃតែងសេចក្តី និងការផ្តល់អំណះអំណាងគាំទ្រមតិរបស់ខ្លួន។ ក្នុងនោះ អត្ថបទចំនួន៣នឹងត្រូវបានជ្រើសរើសចុងក្រោយជាជ័យលាភីប្រចាំឆ្នាំ២០១៤ ដោយគណៈកម្មការនៅភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៤។

សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ http://essaycontest.csaj-khmer.org ឬទាក់ទងមកយើងខ្ញុំតាមរយៈអ៊ីមែល essay14@csaj-khmer.org ឬតាមរយៈទូរស័ព្ទ (+81)-80-4816-8986 (ប្រទេសជប៉ុន)។

*រក្សាសិទ្ធិដោយ © ២០១៤ សមាគមនិស្សិតខ្មែរនៅប្រទេសជប៉ុន*